ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋសភា
អគ្គលេខាធិការដ្ឋាន

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧
# ថ្ងៃព្រហស្បតិ៍ ទី២៥ ខែធ្នូ ឆ្នាំ២០២៥

អគ្គលេខាធិការដ្ឋានរដ្ឋសភាមានកិត្តិយសសូមជម្រាបជូនសាធារណជនមេត្តាជ្រាបថា នៅថ្ងៃព្រហស្បតិ៍ ៦កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ វេលាម៉ោង ៨:០០នាទី រដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា បានបន្តសម័យប្រជុំលើកទី៥ នីតិកាលទី៧ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា ដោយមានវត្តមានសមាជិក សមាជិការដ្ឋសភាពេលផ្តើមសម័យប្រជុំចំនួន **១១០**រូប។

អង្គសភាបានអនុម័តយល់ព្រមរបៀបវារៈសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧ ចំនួន៤ ដោយទទួលបានចំនួន **១១១ សំឡេង**នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

អង្គសភាបានបន្តនីតិវិធី ទៅតាមរបៀបវារៈទាំង៤ នៃសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧ដែលមានលទ្ធផលដូចតទៅ៖

**១**-ការពិភាក្សា និងអនុម័តសេចក្តីព្រាងច្បាប់ស្តីពី អាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ។

សេចក្តីព្រាងច្បាប់ស្តីពី អាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា គឺបានរៀបចំឡើងដើម្បីជំនួសច្បាប់ស្តីពី អាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាចាស់ ដែលបានប្រកាសឱ្យប្រើតាំងពីឆ្នាំ២០០៨ ដែលពុំបានគ្របដណ្តប់អស់នូវសកម្មភាពអាកាសចរណ៍ថ្មីៗ ដែលកំពុងមានការវិវត្តរីកចម្រើនយ៉ាងខ្លាំងនៅក្នុងពិភពលោក។ ដើម្បីបំពេញនូវមូលដ្ឋានគតិយុត្តឱ្យបានគ្រប់គ្រាន់សម្រាប់ការគ្រប់គ្រង និងអភិវឌ្ឍវិស័យអាកាសចរណ៍នៅព្រះរាជាណាចក្រកម្ពុជា ទើបរាជរដ្ឋាភិបាលដែលមានរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិលជាសេនាធិការបានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី អាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ជាថ្មី ដើម្បីធានាសុវត្ថិភាព សន្តិសុខ សណ្តាប់ធ្នាប់ ប្រតិបត្តិការអាកាសចរណ៍ស៊ីវិល ជំរុញការអភិវឌ្ឍការដឹកជញ្ជូនតាមផ្លូវអាកាសប្រកបដោយចីរភាព កាលានុវត្តភាពវិនិយោគ ការប្រកួតប្រជែង និងរួមចំណែកការពារបរិស្ថាន ព្រមទាំងលើកកម្ពស់ផលប្រយោជន៍សមស្របរបស់អ្នកប្រើប្រាស់សេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសនៅកម្ពុជា។

-សេចក្តីព្រាងច្បាប់ស្តីពី អាកាសចរណ៍ស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា មានចំនួន ២៥ជំពូក ចែកចេញជា១០៤មាត្រា។



វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១៣ ៥៣៥, ២២០ ៦២៨
ទូរសារ: (៨៥៥-២៣) ២២០ ៦២៥ សារអេឡិចត្រូនិច:sg@na.gov.kh គេហទំព័រ: www.na.gov.kh

-លោកជំទាវ និន សាផុន ប្រធានគណៈកម្មការសាធារណការ ដឹកជញ្ជូន អាកាសចរណ៍ស៊ីវិល ប្រៃសណីយ៍ ទូរគមនាគមន៍ ឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ រ៉ែ ថាមពល ពាណិជ្ជកម្ម រៀបចំដែនដី នគរូបនីយកម្ម និងសំណង់នៃរដ្ឋសភា ជាអ្នករាយការណ៍ជូនអង្គសភា ពីលទ្ធផលនៃការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់។

-ឯកឧត្តម ម៉ៅ ហាវណ្ណាល់ រដ្ឋមន្ត្រី ទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ជាតំណាងរាជរដ្ឋា-ភិបាល និងសហការី ជាអ្នកការពារសេចក្តីព្រាងច្បាប់។

-សមាជិករដ្ឋសភាដែលបានឡើងមានមតិ ក្នុងការពិភាក្សាសេចក្តីព្រាងច្បាប់នេះ មានចំនួន៣រូប គឺ **ឯកឧត្តម ទី សុគន្ធ** តំណាងរាស្ត្រមណ្ឌលខេត្តកណ្តាល **ឯកឧត្តម សេរី កុសល** តំណាងរាស្ត្រមណ្ឌលខេត្តបន្ទាយមានជ័យ និង**ឯកឧត្តម សួស យ៉ារ៉ា** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ។

-អង្គសភាបានអនុម័តយល់ព្រមលើសេចក្តីព្រាងច្បាប់ទាំងមូល ចំនួន **៩៧សំឡេង** នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

**២**- ការពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសហភាពអឺរ៉ុបនិងរដ្ឋសមាជិករបស់ខ្លួន។

សេចក្តីព្រាងច្បាប់ខាងលើ មានភ្ជាប់ដោយកិច្ចព្រមព្រៀង គ្រប់ជ្រុងជ្រោយស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍ សហភាពអឺរ៉ុបនិងរដ្ឋសមាជិក មានខ្លឹមសារចំនួន៣៤ មាត្រា ភ្ជាប់ដោយឧបសម្ព័ន្ធចំនួន១ ដែលមាន១៥ មាត្រា។ កិច្ចព្រមព្រៀងរវាងអាស៊ាន និងសហភាពអឺរ៉ុប ដែលតំណាងឱ្យ ៣៧ប្រទេស រួមមានរដ្ឋសមាជិកអាស៊ាន ១០ប្រទេស និងរដ្ឋសមាជិកអឺរ៉ុប ២៧ប្រទេស គឺជាការបើកចំហរទីផ្សារនៃការដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិរវាងតំបន់ទាំងពីរ។ ព្រះរាជាណាចក្រកម្ពុជា នឹងទទួលបានអត្ថប្រយោជន៍ សម្រាប់ការបង្កើនកិច្ចសហប្រតិបត្តិការរបស់កម្ពុជា ជាមួយរដ្ឋសមាជិកអាស៊ាន និងរដ្ឋសមាជិកនៃសហភាពអឺរ៉ុបក្នុងវិស័យអាកាសចរណ៍ស៊ីវិល ជំរុញការទាក់ទាញវិនិយោគ សេដ្ឋកិច្ច ទេសចរណ៍ ការងារ និងផ្លាស់ប្តូរវប្បធម៌ រវាងប្រជាជន និងប្រជាជននៃតំបន់ទាំងពីរ។

-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងគ្រប់ជ្រុងជ្រោយ ស្តីពីការដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងសហភាពអឺរ៉ុបនិងរដ្ឋសមាជិករបស់ខ្លួន មាន ២មាត្រា។

-**ឯកឧត្តម សួស យ៉ារ៉ា** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាននៃរដ្ឋសភា ជាអ្នករាយការណ៍ជូនអង្គសភា ពីលទ្ធផលនៃការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់។

-**ឯកឧត្តម ម៉ៅ ហាវណ្ណាល់** រដ្ឋមន្ត្រី ទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ជាតំណាងរាជរដ្ឋា-ភិបាល និងសហការី ជាអ្នកការពារសេចក្តីព្រាងច្បាប់។

-អង្គសភាបានអនុម័តយល់ព្រមលើសេចក្តីព្រាងច្បាប់ទាំងមូល ចំនួន **៩៧សំឡេង** នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

៣- ការពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី៣ ស្តីពីការពង្រីកសិទ្ធិហោះហើរទី៥ រវាងភាគីចុះកិច្ចព្រមព្រៀង ក្រោមកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋាភិបាលនៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន។

អត្ថបទសេចក្តីព្រាងច្បាប់ខាងលើ មានភ្ជាប់ដោយពិធីសារទី៣ ស្តីពីការពង្រីកសិទ្ធិហោះហើរទី៥ នៃកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋាភិបាលនៃរដ្ឋសមាជិកសមាគម ប្រជាជាតិអាស៊ីអាគ្នេយ៍ និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន។ ពិធីសារទី៣នេះ នឹងពង្រីកគោលដៅហោះហើរ និងចំនួនជើងហោះហើររវាងរដ្ឋជាសមាជិកអាស៊ាន និងសាធារណរដ្ឋប្រជាមានិតចិន ដែលនឹងផ្តល់ផលប្រយោជន៍ជាច្រើនជូនកម្ពុជា ជាពិសេសនឹងជំរុញដល់ការបង្កើនការដឹកជញ្ជូន ពាណិជ្ជកម្ម ទេសចរណ៍ វិនិយោគ ការងារ និងសេដ្ឋកិច្ច។

-សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារទី៣ ស្តីពីការពង្រីកសិទ្ធិហោះហើរទី៥ រវាងភាគីចុះកិច្ចព្រមព្រៀង ក្រោមកិច្ចព្រមព្រៀងដឹកជញ្ជូនតាមផ្លូវអាកាស រវាងរដ្ឋាភិបាលនៃរដ្ឋសមាជិកសមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងរដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតចិន មាន២មាត្រា។

-**ឯកឧត្តម សួស យ៉ារ៉ា** ប្រធានគណៈកម្មការកិច្ចការបរទេស សហប្រតិបត្តិការអន្តរជាតិ និងព័ត៌មាននៃរដ្ឋសភា ជាអ្នករាយការណ៍ជូនអង្គសភា ពីលទ្ធផលនៃការពិនិត្យសិក្សាសេចក្តីព្រាងច្បាប់។

-**ឯកឧត្តម ម៉ៅ ហាវណ្ណាល់** រដ្ឋមន្ត្រី ទទួលបន្ទុករដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ជាតំណាងរាជរដ្ឋាភិបាល និងសហការី ជាអ្នកការពារសេចក្តីព្រាងច្បាប់។

-អង្គសភាបានអនុម័តយល់ព្រមលើសេចក្តីព្រាងច្បាប់ទាំងមូល ចំនួន **៩៧សំឡេង** នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

៤- ការពិភាក្សា និងអនុម័ត សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១១ និងទី១២ នៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាស ក្រោមកិច្ចព្រមព្រៀងក្របខ័ណ្ឌអាស៊ានស្តីពីសេវាកម្ម។

សេចក្តីព្រាងច្បាប់ខាងលើ មានភ្ជាប់ដោយពិធីសារអនុវត្តកញ្ចប់ កិច្ចសន្យាទី១១ ដែលមានខ្លឹមសារព្រមព្រៀងចំនួន ៦ចំណុច និងពិធីសារអនុវត្តកញ្ចប់កិច្ចសន្យាទី១២ មានខ្លឹមសារព្រមព្រៀងចំនួន ៦ចំណុច ។ ការអនុម័តសេចក្តីព្រាងច្បាប់នេះ នឹងបានផ្តល់នូវអត្ថប្រយោជន៍ដល់កម្ពុជាដូចជា៖ បំពេញកាតព្វកិច្ចក្នុងនាមរដ្ឋសមាជិក អាស៊ានដើម្បីសម្រេចបាននូវចក្ខុវិស័យនៃសហគមន៍សេដ្ឋកិច្ចអាស៊ានតែមួយ តាមរយៈការកសាងទីផ្សារអាកាសចរណ៍អាស៊ានតែមួយ ជំរុញសមាហរណកម្មនៅក្នុងតំបន់អាស៊ាននៃវិស័យអាកាសចរណ៍ស៊ីវិល តាមរយៈការបើកចំហទីផ្សារបន្ថែមនៃសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសអន្តរជាតិ និងទាក់ទាញការវិនិយោគលើផ្នែកសេវាកម្មដឹកជញ្ជូនតាមផ្លូវអាកាសនៅកម្ពុជា ពីបណ្តាប្រទេសសមាជិកអាស៊ាន។

-អង្គសភាបានអនុម័តយល់ព្រមលើសេចក្តីព្រាងច្បាប់ទាំងមូល ចំនួន **៩៧សំឡេង** នៃចំនួនសមាជិករដ្ឋសភាទាំងមូល។

សម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧ បានពិភាក្សា និងអនុម័តនូវរបៀបវារៈទាំង៤ ចប់សព្វគ្រប់ នៅវេលាម៉ោង ១៦:៤៥នាទី នាថ្ងៃខែឆ្នាំដដែល។ អាស្រ័យដោយអង្គសភា មិនទាន់មានរបៀបវារៈ សម្រាប់ធ្វើការពិភាក្សា និងអនុម័តបន្ត អង្គសភាបានលើកសម័យប្រជុំរដ្ឋសភា លើកទី៥ នីតិកាលទី៧ មួយរយៈពេលសិន។

បំពោះព័ត៌មានទាក់ទងនឹងការបន្តសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៧ នឹងជម្រាបជូន និងទូលថ្វាយនៅពេលក្រោយតាមរយៈលិខិតអញ្ជើញ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន ជ្រាបជាព័ត៌មាន៕

ថ្ងៃព្រហស្បតិ៍ ៦កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥

**អគ្គលេខាធិការដ្ឋានរដ្ឋសភា**